សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ ប្រអប់សំបុត្រ ៤៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទៈ (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារៈ (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦ អ៊ីមែលៈ contact@licadho-cambodia.org

# ឆ្នាំ២០១៤ នាំមកនូវរលកថ្មីនៃជម្លោះដីធ្លីនៅកម្ពុជា

ចំនួនគ្រួសារ ដែលរងគ្រោះដោយសារជម្លោះដីធ្លីដែលពាក់ព័ន្ធនឹងរដ្ឋ និងភ្នាក់ងាររដ្ឋនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០០ បានកើនឡើងលើសកន្លះលាននាក់ហើយ គិតមកត្រឹមខែមិនានេះដោយយោងតាមទិន្នន័យដែលប្រមូលដោយអង្គការលីកាដូ[1]។

ដើម្បីបង្ហាញពីបញ្ហាសំខាន់ៗទាំងនេះ អង្គការលីកាដូ បានចេញផ្សាយវីដេអូថ្មីមួយ រួមជាមួយនឹងផែនទីដើម្បីបង្ហាញពីទីតាំងដែលកើតមានជម្លោះដីធ្លី និងការកើនឡើងយ៉ាងឆាប់រហ័សនៃការរំលោភដីធ្លី ដែលបានកើតឡើងរយៈពេល ១៣ ឆ្នាំកន្លងមកនេះ។ រយៈពេលប៉ុន្មានខែដើមឆ្នាំ២០១៤ នេះ រលកនៃការរំលោភដីធ្លី ដែលមានអំពើហិង្សានៅតែបន្តកើតមានឡើង ដែលមានផលប៉ះពាល់អាក្រក់ដល់ប្រជាពលរដ្ឋចំនួនជាង ២,២៤៦ គ្រួសារនៅស្ទើរគ្រប់ខេត្ត ដែលអង្គការលីកាដូ បានធ្វើការឃ្លាំមើល។

ព្រឹត្តិការណ៍នៃបញ្ហាមួយចំនួនចុងក្រោយនេះ (រួមជាមួយនឹងផែនទី) បានបង្ហាញឲ្យឃើញពីកម្រិតនៃការបរាជ័យរបស់រាជរដ្ឋភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហាដែលកំពុងបន្តកើតមានទាំងនេះ។

ណាលី ពីឡុក នាយិកាអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានមានប្រសាសន៍ថា៖ “តួលេខចុងក្រោយទាំងនេះ គឺពិតជាគួរឲ្យភ្ញាក់ផ្អើល”។ អ្នកនាងក៏បានបន្តទៀតថា៖ “កន្លះលាននាក់នៃប្រជាពលរដ្ឋដែលបានរងគ្រោះ គឺពិតជារឿងមួយដែលគួរឲ្យខ្មាស់អៀនមួយ (ចំនួននីមួយៗតំណាងឲ្យជីវិតដែលត្រូវបានបំផ្លាញយ៉ាងខ្លាំង ហើយនិងបុគ្គលម្នាក់ៗដែលប្រឈមមុខនឹងការលំបាកខ្លាំង និងរយៈពេលយូរ)។ ប្រសិនបើគ្មានដីធ្លីអ្នកទាំងនោះនឹងលែងមានមធ្យោបាយក្នុងការបំពេញតម្រូវការជាមូលដ្ឋាន សម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេ។ រាជរដ្ឋាភិបាលគួរតែធ្វើសកម្មភាពដើម្បីបញ្ឈប់ជំងឺនៃការរំលោភដីធ្លីដ៏រីករាលដាលនេះ”។

ចាប់តាំងពីដើមឆ្នាំ២០១៤ អ្នកឃ្លាំមើលមួយចំនួនរបស់អង្គការលីកាដូ បានកត់ត្រាទុកនូវជម្លោះដីធ្លីមួយចំនួនដូចខាងក្រោម៖

- ក្នុងខែមករា ក្រុមជនជាតិដើមភាគតិចគួយរាប់រយនាក់ ដែលរស់នៅខេត្តព្រះវិហារបានចាប់ផ្តើមធ្វើការតវ៉ាប្រឆាំងនឹងក្រុមហ៊ុនចិនចំនួនប្រាំ គឺ Lan Feng, Rul Feng, Heng Rul, Heng Yue និង Heng Non ដែលធ្វើការ កាប់បំផ្លាញព្រៃសហគមន៍។ ក្រុមហ៊ុននេះ បានទទួលការផ្តល់ដីសម្បទានសេដ្ឋកិច្ចចំនួន ៥ កន្លែងផ្សេងៗគ្នា ដែលអាចធ្វើឲ្យក្រុមហ៊ុននេះរួចផុតពីការកំណត់ទំហំដីតាមផ្លូវច្បាប់សម្រាប់ការសម្បទានដីចំនួន១០,០០០ហិកតានេះ។ ក្រុមជនជាតិដើមភាគតិចទាំងអស់នេះបានបន្តការតវ៉ារបស់ខ្លួន

[1] ជម្លោះដីធ្លីដែលកើតមានឡើងនៅចន្លោះខែមករា ឆ្នាំ២០០០ ដល់ខែមីនា ឆ្នាំ២០១៤។ ជម្លោះទាំងនេះ បានកើតឡើងស្ទើរតែនៅក្នុង ១៣ ខេត្ត ដែលបានអង្កេតដោយអង្គការលីកាដូ ដែលស្មើនឹងពាក់ជាងកណ្តាលនៃផ្ទៃប្រទេសកម្ពុជា។ ដើម្បីរកឃើញតួលេខចំនួន ៥០០,៧០១ អង្គការលីកាដូ បានគុណចំនួនគ្រួសារដែលរងគ្រោះក្នុងមួយឆ្នាំៗ ជាមួយទំហំគ្រួសារជាមធ្យមដែលបានគណនាដោយការស្រាវជ្រាវរបស់រាជរដ្ឋាភិបាល។

**គេហទំព័រ:** licadho-cambodia.org • facebook.com/licadho • twitter.com/licadho
**ការិយាល័យខេត្ត:** បាត់ដំបងៈ (០៥៣) ៩៥២ ៨២៨ • បន្ទាយមានជ័យៈ (០៥៤) ៩៥៨ ៨៦១ • កោះកុងៈ (០៣៥) ៩៣៦ ១១៦ • កំពង់ចាមៈ (០៤២) ៩៤១ ៤៦៤
កំពង់ឆ្នាំងៈ (០២៦) ៩៨៨ ៦៣៧ • កំពង់ស្ពឺៈ (០២៥) ៩៨៧ ២២០ • កំពង់ធំៈ (០៦២) ៩៦១ ២៩២ • កំពតៈ (០៣៣) ៩៣២ ៦៦៣ • ពោធិ៍សាត់ៈ (០៥២) ៩៥១ ៤៩៦
សៀមរាបៈ (០៦៣) ៩៦៤ ០៦៦ • ព្រះសីហនុៈ (០៣៤) ៩៣៣ ៧១៦ • ស្វាយរៀងៈ (០៤៤) ៩៤៥ ៨៣៣

ហើយបច្ចុប្បន្ន អ្នកទាំងនេះ បានចាប់ផ្តើមសម្រាកនៅក្នុងព្រៃដើម្បីព្យាយាមការពារព្រៃឈើក្នុងតំបន់នេះ។

- នៅថ្ងៃទី៥ ខែកុម្ភៈ ផ្ទះរបស់ប្រជាពលរដ្ឋចំនួន ៨៧គ្រួសារ ដែលរស់នៅស្រុកគីរីសាគរ ខេត្តកោះកុង ត្រូវបានបំផ្លិចបំផ្លាញដោយក្រុមហ៊ុនចិន Union Development Group ដើម្បីអភិវឌ្ឍគម្រោងទេសចរណ៍ដ៏ធំមួយ។ ការបំផ្លិចបំផ្លាញផ្ទះរបស់ក្រុមប្រជាពលរដ្ឋទាំងនេះ បានធ្វើឲ្យក្រុមគ្រួសាររបស់ពួកគេគ្មានទីកន្លែងដែលត្រូវទៅហើយត្រូវបង្ខំចិត្តបោះជំរុំនៅក្បែរនោះ ដើម្បីស្នាក់នៅបណ្តោះអាសន្ន។ ក្រុមគ្រួសាររបស់ប្រជាពលរដ្ឋទាំងនោះ ពុំទាន់បានទទួលសំណងអ្វីពីការបំផ្លិចបំផ្លាញនេះនៅឡើយទេ ហើយនៅពេលដែលអ្នកទាំងនេះ ធ្វើការតវ៉ាដើម្បីឲ្យអាជ្ញាធរដឹងលឺអំពីបញ្ហារបស់អ្នកទាំងនោះ ពួកគេបែរជាត្រូវបានរងការគំរាមកំហែងពីសំណាក់កងសន្តិសុខ និងយោធាទៅវិញ។

- ថ្ងៃទី៤ ខែមីនា ក្នុងសង្កាត់បឹងកក់មួយ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ជនមិនស្គាល់មុខចំនួនពីរនាក់បានវាយប្រហារលោក លី ស្រៀងខេង ហើយបានវាយលោកដោយញញួរ ខណៈពេលដែលលោកធ្វើដំណើរទៅផ្សារ។ លោក លី ស្រៀងខេង រួមជាមួយក្រុមគ្រួសារចំនួនបីគ្រួសារផ្សេងទៀតមានការជាប់ទាក់ទងជាមួយជម្លោះដីធ្លីដ៏រ៉ាំរ៉ៃជាមួយក្រុមហ៊ុន Khun Sea នៅពេលដែលក្រុមហ៊ុននេះ បានទិញដីសាលាសង្កាត់ ដែលមួយផ្នែកនៃដីនោះ ជាន់ជាមួយដីរបស់ក្រុមគ្រួសារដែលប៉ះពាល់។ នេះមិនមែនជាសកម្មភាពវាយប្រហារលើកទីមួយទៅកាន់រូបលោកនោះទេ ការវាយប្រហារកាលពីពេលមុនរួមមានការប៉ុនប៉ងដុតផ្ទះ ការយកសត្វពស់ដែលមានពិសទៅដាក់ក្នុងផ្ទះរបស់លោក និងការវាយប្រហារលើរូបរាងកាយរបស់លោក។

- នៅថ្ងៃទី១០ ខែមីនា ក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ មន្ត្រីបរិស្ថានរបស់រាជរដ្ឋាភិបាល បានបាញ់គ្រាប់កាំភ្លើងទៅលើអាកាស ដើម្បីធ្វើការគំរាមកំហែងដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងជម្លោះដីធ្លីជាមួយក្រុមហ៊ុន MDS Import Export Company។ ឧកញ៉ា ទ្រី ភាព ជាម្ចាស់ក្រុមហ៊ុននេះ ហើយក៏ជាអ្នកដែលមានជម្លោះជាមួយនឹងប្រជាពលរដ្ឋចំនួន ២៣ គ្រួសារទាក់ទងនឹងការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស។ ក្រុមគ្រួសារទាំងអស់នោះ រួមមានទាំងក្រុមគ្រួសារអតីតខ្មែរក្រហម ដែលបានតាំងទីលំនៅក្នុងតំបន់នេះ បន្ទាប់ពីមានការធ្វើសមាហ័រណកម្មប្រទេសកាលពីចុងទសវត្សន៍ឆ្នាំ៩០។

- នៅថ្ងៃទី១១ ខែមីនា ជម្លោះដីធ្លីដ៏រ៉ាំរ៉ៃមួយលើដីព្រៃរបស់រដ្ឋចំនួនជាង ២០០ហិកតា ដែលមានទីតាំងនៅក្នុងឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀងបានកើតឡើងនៅពេលដែលប្រជាពលរដ្ឋប្រមាណជា ៦០០គ្រួសារដែលមកពីបណ្តាភូមិចំនួនប្រាំបានធ្វើការប្រមូលផ្តុំគ្នារាំងការរុករានដីមានជម្លោះពីសំណាក់កងសន្តិសុខ និងការប្រើប្រាស់គ្រឿងចក្រធំៗ។

- ដូចគ្នាដែរនៅក្នុងខែមីនា នេះដែរ ប្រជាពលរដ្ឋដែលមកពីតំបន់អារ៉ែង ក្នុងឃុំជំនប់ ស្រុកថ្មបាំង ខេត្តកោះកុងបានធ្វើការតវ៉ាប្រឆាំងជាមួយនឹងក្រុមហ៊ុនចិន Sinohydro ដើម្បីរាំងបុគ្គលិកក្រុមហ៊ុនចិននោះដែលបានប្រើប្រាស់គ្រឿងចក្រចូលទៅកាន់សហគមន៍របស់អ្នកទាំងនេះ។ ក្រុមហ៊ុន Sinohydro គឺជា

ក្រុមហ៊ុនចុងក្រោយបំផុតដែលមានការពាក់ព័ន្ធនឹងគម្រោងទំនប់វារីអគ្គិសនីមួយ ដែលពោរពេញទៅដោយបញ្ហា ហើយដែលបង្ខំឲ្យមានការផ្លាស់ប្តូរទីតាំងថ្មីនៃភូមិជាច្រើនពីក្នុងតំបន់អាងស្តុកទឹកដែលបានកំណត់ក្នុងគម្រោងអភិវឌ្ឍន៍នោះទៀតផង។ ប្រជាពលរដ្ឋទាំងនោះ មានការខឹងសម្បាយ៉ាងខ្លាំងចំពោះភាពខ្វះខាតការប្រឹក្សា និងការមិនបានគោរពតាមលក្ខខណ្ឌជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងនោះ និងការបំផ្លិចបំផ្លាញបរិស្ថាន។

រលកនៃបញ្ហាដែលនៅតែកើតមានឡើងជាថ្មីនេះ បានកើតឡើងបន្ទាប់ពីបទបញ្ជាខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលដែលបានបង្គាប់ឲ្យផ្អាកការសម្បទានដីសេដ្ឋកិច្ចថ្មីៗ ហើយបញ្ជាឲ្យមានការត្រួតពិនិត្យសារឡើងវិញជាលក្ខខណៈប្រព័ន្ធសម្រាប់ដីសម្បទាននាពេលកន្លងមក។ កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅក្រោមការឧបត្ថម្ភ ដោយផ្ទាល់ពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានផ្អែកលើកម្លាំងនិស្សិតស្ម័គ្រចិត្តជាង ២,០០០នាក់ បានធ្វើដំណើរទូទាំងប្រទេសដើម្បីធ្វើការវាស់វែងដី និងចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ត្រូវបានអនុវត្តនៅចុងឆ្នាំ២០១២ និងដើមឆ្នាំ២០១៣ ក្រោយពីបទបញ្ជាត្រូវបានចេញ។ កម្មវិធីដែលបានរំលងស្ថាប័នរដ្ឋដែលមានសមត្ថកិច្ចពាក់ព័ន្ធនេះ គឺធ្វើឡើងដោយមិនមានតម្លាភាព និងមិនមានការត្រួតពិនិត្យដោយឯករាជ្យឡើយ។

នេះបានបង្ហាញឲ្យឃើញថា សេចក្តីបង្គាប់របស់រាជរដ្ឋាភិបាលមិនមានប្រសិទ្ធិភាពពេញលេញឡើយ ដោយសារតែមិនមានភស្តុតាងនៃការពិនិត្យឡើងវិញនូវដីសម្បទានដែលបានផ្តល់រួចហើយ និងដែលមានប្រសិទ្ធិភាពណាមួយកើតមានឡើងនោះទេ។ ការបរាជ័យក្នុងការត្រួតពិនិត្យនេះ គឺជាបញ្ហាមួយដ៏ធ្ងន់ធ្ងរ ដោយសារតែសេចក្តីប្រកាសថ្មីៗរបស់រាជរដ្ឋាភិបាល ថានឹងចាត់ចែងជាថ្មីនូវដីសម្បទានបានផ្តល់កន្លងមកដែលមិនមានការប្រើប្រាស់។

នេះក៏បានបង្ហាញយ៉ាងច្បាស់ ថាកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិបានបរាជ័យក្នុងការបញ្ចប់ជម្លោះ៖ ក្នុងតំបន់មួយក្នុងប្រទេសកម្ពុជា ដែលរាជរដ្ឋាភិបាលបានអះអាងថាខ្លួនបានចាត់ចែងឡើងវិញពីការសម្បទានឲ្យក្រុមហ៊ុន ហើយថែមទាំងបានផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋទៀតផង គឺជាតំបន់មួយដែលស្ថិតនៅក្នុងខេត្តព្រះវិហារ ដែលជាតំបន់សហគមន៍ជនជាតិដើមភាគតិចគួយ កំពុងធ្វើការតស៊ូ ដើម្បីថែរក្សាព្រៃឈើរបស់ពួកគេ ដូចដែលបានរៀបរាប់ខាងលើ។

អង្គការលីកាដូ បន្តផ្តល់យោបល់របស់ខ្លួនមួយចំនួនទៅកាន់រាជរដ្ឋាភិបាលដូចជា៖

- បញ្ឈប់ការបណ្តេញចេញ ហើយផ្តល់សំណងឲ្យបានគ្រប់គ្រាន់ និងយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋដែលទទួលរងការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងដោយរងគ្រោះពីការរំលោភដីធ្លី។
- អនុវត្តការសន្យារបស់ខ្លួនក្នុងការត្រួតពិនិត្យឡើងវិញចំពោះការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងការសម្បទានដទៃទៀត ហើយបញ្ចប់ដំណើរការរបស់ខ្លួនក្នុងការផ្តល់ដីសម្បទានជាថ្មី រហូតដល់ការត្រួតពិនិត្យបានបញ្ចប់។

- អនុវត្តការវាស់វែង និងដំណើរការបែងចែកដីជាសាធារណៈ និងមានតម្លាភាពឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ហើយព្រមទាំងធានាឲ្យបានថាការអនុវត្តកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋនេះ ត្រូវតែបានធ្វើឡើងពីសំណាក់ស្ថាប័នរដ្ឋដែលមានការពាក់ព័ន្ធនឹងបញ្ហានេះ។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ*

- អ្នកនាង ណាលី ពីឡូក នាយិកាអង្គការសិទ្ធិមនុស្ស លីកាដូ ទូរស័ព្ទលេខៈ ០១២ ៨០៣ ៦៥០ (ភាសាបារាំង និងអង់គ្លេស)
- លោក អំ សំអាត អ្នកសម្របសម្រួលផ្នែកបច្ចេកទេសស៊ើបអង្កេតនៃអង្គការលីកាដូ ទូរស័ព្ទលេខៈ ០១២ ៣២៧ ៧៧០ (ជាភាសាខ្មែរ)